**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

*រាជធានីភ្នំពេញ. ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៩*

*លេខ: ៥៧៣៩ អស១.កបទ.សអ*

***ជំរាបមក***

***លោកជំទាវ ឯកអគ្គរាជទូតកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ***

***កម្មវត្ថុ:*** *សំណើលុបការផ្សព្វផ្សាយលើគេហទំព័រថៃ ស្តីពីការបាត់បង់ទឹកដីថៃជាមួយប្រទេសជិតខាង។*

***យោង:*** *លិខិតលេខ ០៦៩៨/០៩/សកប ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៩ របស់ស្ថានទូត**កម្ពុជា** នៅ**បាងកក** ។*

*សូមជំរាបលោកជំទាវថា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ណែនាំអោយលោកជំទាវ **តទ៉ាជាបន្ទាន់**ទៅក្រសួងការបរទេសថៃ ដើម្បីលុបចោលនូវ Video Clip ចេញពីគេហទំព័រផ្សព្វផ្សាយរបស់ថៃ ដោយលើកហេតុផលដូចតទៅ ៖*

- *ជាភ្លើងដុតកំហឹងប្រជាជាតិទាំងពីរ ដែលតាមការពិតប្រជាជាតិទាំងពីរនេះចង់បានសន្តិភាព សន្តិសុខ មិត្តភាព សហប្រតិបត្តិការ និងជាអ្នកភូមិផងរបងជាមួយ ។*
- *បើនិយាយតាមសច្ចធម៌នៃប្រវត្តិសាស្ត្រ **កម្ពុជា**ទេដែលបាត់បង់ទឹកដីដ៏សន្ធឹកសន្ធាប់រួញតូចដូចសព្វថ្ងៃ ។*
- *ទោះជាយ៉ាងណាយើងមិនគួររំលឹកពីអតីតកាលដ៏ជូរចត់ទេ យើងគួរនាំគ្នាគោរពតាមតែខ្សែព្រំដែន ដែលអាណាព្យាបាល**បារាំង**បានបន្សល់នោះ គឺខ្សែព្រំដែនដែលយើងមានសព្វថ្ងៃ ហើយដែលអន្តរជាតិទទួលស្គាល់ និងខិតខំកសាងខ្សែព្រំដែននេះ អោយក្លាយទៅជាខ្សែព្រំដែនសន្តិភាព មិត្តភាព និងអភិវឌ្ឍន៍ ។*

*សូម **លោកជំទាវ** ចាត់វិធានការអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត រួចរាយការណ៍មកក្រសួងវិញឱ្យបានឆាប់ ។*

***រដ្ឋមន្ត្រីស្តីទី***

***ឡុង វិសាលោ***

***<u>ចម្លងជូន៖</u>***

*- ទីស្តីការគណៈរដ្ឋមន្ត្រី (ខុទ្ទកាល័យលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ)*

*- ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី***

*- ក្រសួងព័ត៌មាន*

*- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ*

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា